អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គភាពគាំពារជនរងគ្រោះ
**Victims Support Section**
**Section d'appui aux victimes**

ថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១៥

# សេចក្តីប្រកាសព័ត៌មាន
# ពិធីសម្ពោធបូជនីយ៍ដ្ឋាននៃការចងចាំ និងរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅ សារៈមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនឹងធ្វើពិធីសម្ពោធបូជនីយ៍ដ្ឋាននៃការចងចាំ និងរំឭកវិញ្ញាណក្ខន្ធ ជនរងគ្រោះដែលបានបាត់បង់ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ វេលាម៉ោង ៨: ៣០ នាទីព្រឹក នៅសារៈមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។

ពិធីសម្ពោធនេះនឹងប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលកម្ពុជាសម្រាប់ដំណើរការសាលាក្តីខ្មែរក្រហម និង ឯកឧត្តម Joachim Baron von Marschall ឯកអគ្គរដ្ឋទូតសហព័ន្ធអាល្លឺម៉ង់ ប្រចាំប្រទេសកម្ពុជា ព្រមទាំងមានការចូលរួមដោយអ្នករស់រានមានជីវិតពីគុកទួលស្លែង ដើមបណ្តឹងរដ្ឋប្បវេណី នៃ អ.វ.ត.ក សមាគមជនរងគ្រោះ និងអ្នកពាក់ព័ន្ធដទៃទៀត។ បូជនីយ៍ដ្ឋានេះ សាងសង់ឡើង ដើម្បីជាការចងចាំងខួទិសដល់វិញ្ញាណក្ខន្ធជនរងគ្រោះដែលបានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសជនរងគ្រោះចំនួន ១២២៧២ នាក់ ដែលបានជាប់ឃុំឃាំងខុសច្បាប់នៅ គុកទួលស្លែង (មន្ទីរ ស-២១) ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះឆ្នាំ ១៩៧៥ ដល់ ១៩៧៩។ នៅទីនោះពួកគេបានស្ថិតនៅក្នុងស្ថានភាពអមនុស្សធម៌ និងត្រូវបានគេបង្ខំឲ្យធ្វើការងារ ធ្វើទារុណកម្ម ត្រូវបានសម្លាប់ និងបាត់បង់ជីវិតនៅវាលពិឃាតជើងឯក និងព្រៃស (មន្ទីរ ស-២៤) ដែលជាការដ្ឋានបង្ខំឲ្យធ្វើការងារ ។

បូជនីយ៍ដ្ឋាន ដែលសាងសង់លើផ្ទៃក្រឡាចំនួន ៤០០ ម៉ែត្រការ៉េ និងមានកំពស់ ៦ ម៉ែត្រ ត្រូវបានរៀបចំប្លង់ និងសាងសង់ឡើងដោយ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (អគ្គនាយកដ្ឋានបេតិកភណ្ឌ) ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយនឹងអង្គភាពគាំពារជនរងគ្រោះនៃអ.វ.ត.ក និងស្ថាប័នពាក់ព័ន្ធ និងមានជំនួយហិរញ្ញវត្ថុពីក្រសួងសហប្រតិបត្តិការ

សេដ្ឋកិច្ច និងការអភិវឌ្ឍន៍អាល្លឺម៉ង់ (BMZ)/GIZ.។



**រូបភាពបូជនីយដ្ឋាននៃការចងចាំ និងរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ**

ការសាងសង់បូជនីយដ្ឋាននៅសារមន្ទីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងគឺជាគម្រោងមួយស្ថិតនៅក្រោមភារកិច្ច និងការទទួលខុសត្រូវរបស់អង្គភាពគាំពារជនរងគ្រោះក្រោមក្របខ័ណ្ឌនៃកម្មវិធី និងវិធានការក្រៅបច្ចេកទេសតុលាការដើម្បីផ្តល់ផលប្រយោជន៍ដ៏ទូលំទូលាយដល់ជនរងគ្រោះ។

| **សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖** |
|---|
| លោក នេត្រ ភក្ត្រា<br>មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម<br>ទូរស័ព្ទដៃលេខ៖ ៨៥៥ (0) ១២ ៤៨៨ ១៥៦<br>ទូរស័ព្ទលើតុលេខ៖ ៨៥៥ (0) ២៣ ៨៦១ ៥៦៤<br>សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh |

| **ទំនាក់ទំនងនៅអង្គភាពគាំពារជនរងគ្រោះ** | |
|---|---|
| លោក ហង្ស វណ្ណៈ ប្រធានអង្គភាពគាំពារជនរងគ្រោះ<br>សារអេឡិចត្រូនិកៈ hang.vannak@eccc.gov.kh<br>ទូរស័ព្ទៈ ៨៥៥ (0) ២៣ ៨៦១ ៥00 | លោក TRUEMPER Thomas ភ្នាក់ងារសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) ទីប្រឹក្សានៃកម្មវិធីសំណង<br>សារអេឡិចត្រូនិក៖ TRUEMPER.Thomas@eccc.gov.kh<br>ទូរស័ព្ទៈ ៨៥៥ (0) ២៣ ៨៦២ ១0៣ |